**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៥៣៧ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ ទាលអូរភ្លី ស្ថិតនៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ២១៩ប្រក.កសក.ចុះថ្ងៃទី២១ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្ម រាជធានី ខេត្តនិងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឲ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## សម្រេច

**ប្រការ១ .—**

ត្រូវបានបង្កើតតំបន់ព្រៃសហគមន៍វាលអូរក្តី សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើ មានទីតាំងស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ។

**ប្រការ២ .—**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណងៈ

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះ និងអភិវឌ្ឍន៍ព្រៃសហគមន៍ឲ្យមានចីរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាននិងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។

**ប្រការ៣ .—**

តំបន់ព្រៃសហគមន៍វាលអូរក្តីមានផ្ទៃក្រឡាសរុបទំហំ៤ ២១៨(បួនពាន់ពីររយដប់ប្រាំបី)ហិកតា ដូចមានផែនទីភ្ជាប់មកជាឧបសម្ព័ន្ធនៃប្រកាសនេះ និងមាននិយាមកាចំណុចគោល(Datum: WGS1984)ដូចខាងក្រោមៈ

| ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) | ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) | ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) |
|---|---|---|---|---|---|---|---|---|
| 1 | 540449 | 1405640 | 19 | 530381 | 1396610 | 37 | 530386 | 1403300 |
| 2 | 540488 | 1404550 | 20 | 530018 | 1396380 | 38 | 530827 | 1403300 |
| 3 | 539603 | 1404070 | 21 | 529700 | 1396420 | 39 | 531045 | 1403670 |
| 4 | 538977 | 1403760 | 22 | 529984 | 1396930 | 40 | 531226 | 1403910 |
| 5 | 538136 | 1403310 | 23 | 530525 | 1397330 | 41 | 531457 | 1404220 |
| 6 | 536934 | 1402570 | 24 | 530696 | 1397410 | 42 | 531490 | 1404310 |
| 7 | 536163 | 1402100 | 25 | 530794 | 1397520 | 43 | 533586 | 1404320 |
| 8 | 535533 | 1401280 | 26 | 530844 | 1397840 | 44 | 533599 | 1404630 |
| 9 | 534856 | 1400660 | 27 | 530836 | 1398010 | 45 | 535924 | 1404610 |
| 10 | 534367 | 1400100 | 28 | 530877 | 1398400 | 46 | 535924 | 1405380 |
| 11 | 534102 | 1399800 | 29 | 530844 | 1398750 | 47 | 536063 | 1405360 |
| 12 | 533593 | 1399220 | 30 | 530943 | 1399040 | 48 | 536457 | 1405200 |
| 13 | 532842 | 1398100 | 31 | 530891 | 1399320 | 49 | 536857 | 1405210 |
| 14 | 532042 | 1396750 | 32 | 530835 | 1399770 | 50 | 537422 | 1405670 |
| 15 | 531889 | 1396050 | 33 | 530461 | 1400250 | 51 | 537676 | 1405590 |
| 16 | 531446 | 1396070 | 34 | 530025 | 1400580 | 52 | 538000 | 1405570 |
| 17 | 530930 | 1396300 | 35 | 529764 | 1400990 | 53 | 538419 | 1405690 |
| 18 | 530520 | 1396630 | 36 | 529821 | 1402090 | 54 | 539054 | 1405570 |
| | | | | | | 55 | 539924 | 1405410 |

**ប្រការ៤ .—**

ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

**ប្រការ៥ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ក្រសួងរ៉ែនិងថាមពល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ធំ
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ ៥៣៧ ប្រក.កសក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៧

ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍វាលអូរក្តី ស្ថិតនៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ




ចំណុចនិយាមកាព្រៃសហគមន៍

| ចំណុចគោល | អាប់ស៊ីស | អរដោនេ | ចំណុចគោល | អាប់ស៊ីស | អរដោនេ | ចំណុចគោល | អាប់ស៊ីស | អរដោនេ | ចំណុចគោល | អាប់ស៊ីស | អរដោនេ |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 540449 | 1405640 | 14 | 532042 | 1396750 | 28 | 530877 | 1398400 | 42 | 531490 | 1404310 |
| 2 | 540488 | 1404550 | 15 | 531889 | 1396050 | 29 | 530844 | 1398750 | 43 | 533586 | 1404320 |
| 3 | 539603 | 1404070 | 16 | 531446 | 1396070 | 30 | 530943 | 1399040 | 44 | 533599 | 1404630 |
| 4 | 538977 | 1403760 | 17 | 530930 | 1396300 | 31 | 530891 | 1399320 | 45 | 535924 | 1404610 |
| 5 | 538136 | 1403310 | 18 | 530520 | 1396630 | 32 | 530835 | 1399770 | 46 | 535924 | 1405380 |
| 6 | 536934 | 1402570 | 19 | 530381 | 1396610 | 33 | 530461 | 1400250 | 47 | 536063 | 1405360 |
| 7 | 536163 | 1402100 | 20 | 530018 | 1396380 | 34 | 530025 | 1400580 | 48 | 536457 | 1405200 |
| 8 | 535533 | 1401280 | 21 | 529700 | 1396420 | 35 | 529764 | 1400990 | 49 | 536857 | 1405210 |
| 9 | 534856 | 1400660 | 22 | 529984 | 1396930 | 36 | 529821 | 1402090 | 50 | 537422 | 1405670 |
| 10 | 534367 | 1400100 | 23 | 530525 | 1397330 | 37 | 530386 | 1403300 | 51 | 537676 | 1405590 |
| 11 | 534102 | 1399800 | 24 | 530696 | 1397410 | 38 | 530827 | 1403300 | 52 | 538000 | 1405570 |
| 12 | 533593 | 1399220 | 25 | 530794 | 1397520 | 39 | 531045 | 1403670 | 53 | 538419 | 1405690 |
| 13 | 532842 | 1398100 | 26 | 530844 | 1397840 | 40 | 531226 | 1403910 | 54 | 539054 | 1405570 |
|  |  |  | 27 | 530836 | 1398010 | 41 | 531457 | 1404220 | 55 | 539924 | 1405410 |